# សេចក្តីប្រកាសជាផ្លូវការ របស់អគ្គរដ្ឋអាជ្ញា ៖
## កម្មករទាំងអស់ មានសិទ្ធិទទួលបានកិច្ចការពារផ្នែកការងារ
## មិនថាមានស្ថានភាពអន្តោប្រវេសន៍បែបណានោះឡើយ

ការិយាល័យអគ្គរដ្ឋអាជ្ញា នៃរដ្ឋម៉ាសាឈូសេត សូមបញ្ជាក់អំពីជំហរឥតងាករេរបស់ខ្លួន ថាកម្មករទាំងអស់ មិនថាមានស្ថានភាពអន្តោប្រវេសន៍យ៉ាងណានោះឡើយ គឺសុទ្ធតែទទួលបានកិច្ចការពារ ពីច្បាប់ពលកម្ម និងការងារ។ កិច្ចការពារនៅកន្លែងធ្វើការ រួមមាន៖

- សិទ្ធិទទួលបានប្រាក់ឈ្នួល ក្នុងអត្រាស្របច្បាប់មួយ ដែលត្រូវបើកគ្រប់ចំនួន និង ទៀងទាត់ពេលវេលា រួមទាំង៖
  - ប្រាក់ឈ្នួលអប្បបរមា
  - ប្រាក់ធ្វើការបន្ថែមម៉ោង
  - ប្រាក់ឈ្នួលតាមម៉ោង ជាទូទៅ សម្រាប់គម្រោងសាធារណៈការ
- សិទ្ធិរួចផុតពីការបៀតបៀនផ្លូវភេទ និង ទម្រង់នៃការរើសអើងឯទៀត នៅកន្លែងធ្វើការ
- សិទ្ធិធ្វើការនៅកន្លែងធ្វើការ ដែលមានសុវត្ថិភាព និង ផាសុខភាព
- សិទ្ធិក្នុងការប្រមូលផ្តុំតវ៉ា ឬ បង្កើតសហជីព
- សិទ្ធិក្នុងការទទួលបានការទទួលស្គាល់ត្រឹមត្រូវ ថាជានិយោជិត

យោងតាមខ្លឹមសារនៃការប្រកាសនេះ មានន័យថា ការិយាល័យអគ្គរដ្ឋអាជ្ញា នៃរដ្ឋម៉ាសាឈូសេត ត្រូវអនុវត្ត៖

- យើងត្រូវបម្រើកម្មករគ្រប់រូប មិនថាស្ថានភាពអន្តោប្រវេសន៍គាត់យ៉ាងណានោះឡើយ។
- យើងមិនតម្រូវឱ្យបុគ្គលណាមួយ បង្ហាញស្ថានភាពអន្តោប្រវេសន៍របស់ខ្លួន។

យើងមិនប្រគល់ព័ត៌មានផ្ទាល់ខ្លួនរបស់កម្មករ ទៅអាជ្ញាធរអាមេរិក ផ្នែកពង្រឹងច្បាប់អន្តោប្រវេសន៍ និង គយ ឬ ហៅថា អៃស៍ (ICE) នោះឡើយ (លើកលែងតែមានដីកាកោះ ឬ សេចក្តីបង្គាប់ពីតុលាការ)។

- យើងមិនអត់ឱន ចំពោះទង្វើសងសឹកទៅលើកម្មករ ដែលដាក់ពាក្យប្តឹងនៅការិយាល័យអគ្គរដ្ឋអាជ្ញា ឬ ទង្វើណាមួយប្រឆាំងកម្មករ ដោយគ្រាន់តែគាត់អនុវត្តសិទ្ធិរបស់ខ្លួន។

*កម្មករគ្មានលិខិតអនុញ្ញាតឱ្យធ្វើការ ពីរដ្ឋាភិបាលអាមេរិក ច្រើនតែងាយរងគ្រោះជាពិសេស ដោយការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម។ ផ្នែកយុត្តិធម៌ការងារ នឹងបន្តចាត់វិធានការសមស្រប ក្នុងការពង្រឹងការអនុវត្តច្បាប់ ជួសមុខឱ្យកម្មករទាំងអស់ នៅរដ្ឋម៉ាសាឈូសេត។ បើអ្នកឆ្ងល់អ្វីមួយ ឬ ត្រូវការជំនួយបន្ថែមទៀត អ្នកអាចទាក់ទងផ្នែកយុត្តិធម៌ការងារ តាមទូរស័ព្ទ hotline លេខ៖ (617) 727-3465 ឬ បើកមើលគេហទំព័រ www.mass.gov/ago/fairlabor ។*

**May, 2017**